| លេខាធិការដ្ឋាន REDD+ កម្ពុជា | |
|---|---|
| ចូល | លេខ: 006 លេខា<br>ថ្ងៃទី 12/Nov/2013<br>ម៉ោង 3.45 pm. |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ

## ស្តីពី

## កិច្ចប្រជុំដំបូងនៃក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជា

ឆ្នាំពីរពាន់ដប់បី ខែសីហា ថ្ងៃទីសាមសិប វេលាម៉ោងមួយនិងសាមសិបនាទី នៅសណ្ឋាគារ រ៉ាហ្វល់ឡឺរ៉ូយ៉ាល់ភ្នំពេញ មានកិច្ចប្រជុំដំបូងនៃក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជា ដែលមានសមាមាសភាពចូលរួមចំនួន ១៦នាក់ រួមមាន: តំណាងមកពីវិស័យឯកជន(២នាក់) ស្ថាប័នអប់រំ (១នាក់) អង្គការមិនមែនរដ្ឋាភិបាលជាតិ(២នាក់) អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ(២នាក់) ក្រុមសង្គមស៊ីវិល (២នាក់) បណ្តាញសហគមន៍តំបន់ការពារ(២នាក់) បណ្តាញសហគមន៍ព្រៃឈើ(២នាក់) បណ្តាញ សហគមន៍នេសាទ (១នាក់) និងតំណាងជនជាតិដើមភាគតិច(២នាក់)។

កិច្ចប្រជុំនេះ ក៏បានណែនាំពីសមាសភាពសមាជិកនីមួយៗដោយផ្ទាល់នៃក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជា។ កិច្ចប្រជុំបានគាំទ្រ លោក ឈិត សំអាត តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ ធ្វើជាប្រធានបណ្តោះអាសន្ននៃក្រុមការងារប្រឹក្សាយោបល់ សម្រាប់ការងាររេដ+ កម្ពុជា រហូតដល់មានការបោះឆ្នោតជ្រើសរើសប្រធានក្រុមប្រឹក្សាយោបល់។

សមាជិកនៃក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជា បានពិភាក្សា និងលើកជាយោបល់ដូចខាងក្រោម៖

- លេខាធិការដ្ឋានក្រុមការងាររេដ+កម្ពុជា ត្រូវរៀបចំលទ្ធផលសិក្ខាសាលា ជាពិសេសតួនាទីភារកិច្ចក្រុមប្រឹក្សាយោបល់ ដើម្បីយកជាមូលដ្ឋានកែសម្រួល
- ចំនួនកិច្ចប្រជុំសាមញ្ញ ២ខែម្តង និងមានវិសាមញ្ញករណីចាំបាច់
- ការចូលរួម ប្រសិនបើសមាជិកមិនអាចចូលរួមត្រូវចាត់តាំងតំណាងមកជំនួស
- ត្រូវមានការជ្រើសរើសប្រធាន អនុប្រធាន និងលេខាធិការសម្រាប់ក្រុមប្រឹក្សាយោបល់
- ក្រុមប្រឹក្សាយោបល់នេះមានអាណត្តិចំនួន ៣ឆ្នាំ ក្នុងនោះប្រធាន អនុប្រធាន និងលេខាធិការក្រុមប្រឹក្សាយោបល់ ត្រូវជ្រើសរើសជារៀងរាល់ឆ្នាំ និងមុនពេលបញ្ចប់ អាណត្តិ ១៥ថ្ងៃ
- លេខាធិការដ្ឋានរេដ+កម្ពុជា ជាអ្នកសង្កេតការណ៍ និងជួយធ្វើកំណត់ត្រា ផ្តល់ជូនលេខាធិការរបស់ក្រុមប្រឹក្សាយោបល់
- ប្រធានក្រុមប្រឹក្សាយោបល់ត្រូវធានាឲ្យមានការប្រជុំទៀងទាត់ និងមានរបៀបវារៈប្រជុំ
- ការដឹកនាំការប្រជុំត្រូវប្តូរវេនដោយជ្រើសរើសមុនបញ្ចប់កិច្ចប្រជុំសម្រាប់កិច្ចប្រជុំបន្ទាប់
- ការជ្រើសរើសប្រធានក្រុមប្រឹក្សាត្រូវបោះឆ្នោតក្នុងចំណោមសមាជិកទាំង ១៨រូប
- ការសម្រេចចិត្តផ្ទៃក្នុង ត្រូវយកតាមគោលការណ៍មតិជាឯកឆន្ទ (Consensus) បើមិនអាចសម្រេច បានត្រូវយកសម្លេង ២/៣នៃកូរ៉ុម
- ការប្រជុំត្រូវមានកូរ៉ុម ២/៣ នៃសមាជិកក្រុមប្រឹក្សាយោបល់ទាំងមូល
- ក្នុងករណីមិនមានចែងក្នុងលក្ខន្តិកៈប្រធានជាអ្នកសម្រេច

- លេខាធិការដ្ឋានវេដ+កម្ពុជា ប្រមូលឯកសារដែលមានស្រាប់ពីសិក្ខាសាលា ដើម្បីពិនិត្យក្នុងកិច្ចប្រជុំបន្ទាប់
- មិនចាំបាច់មានលក្ខន្តិក: តែគួរមានបទបញ្ជាផ្ទៃក្នុង និងលក្ខខណ្ឌការងារដែលពណ៌នា លំអិតបានហើយ
- ប្រធានក្រុមប្រឹក្សាយោបល់ត្រូវមានការវាយតម្លៃក្នុងរយ:ពេល ៦ខែម្តង
- សមាជិក ក្រុមប្រឹក្សាយោបល់ ត្រូវមានចំណុចទំនាក់ទំនងកណ្តាលណាមួយ ក្នុងការទទួលលិខិតអញ្ជើញ និងកំណត់ហេតុ ដូច្នេះត្រូវមានលេខទូរស័ព្ទ និងអ៊ីម៉ែល
- ការជ្រើសរើសប្រធានក្រុមប្រឹក្សា អាចធ្វើទៅបានតាមរយ: Online Voting រឺបោះឆ្នោតដោយផ្ទាល់
- សមាជិកក្រុមប្រឹក្សាយោបល់អាចចាត់អ្នកជំនួសក្នុងពេលប្រជុំបាន ប៉ុន្តែត្រូវធានាថាមានការយល់ដឹង និងផ្តល់យោបល់បាន ប៉ុន្តែមិនត្រូវលើសពី ៥០% (៣ដង)ឡើយ
- ការជ្រើសរើសប្រធានក្រុមប្រឹក្សាយោបល់គឺត្រូវធ្វើនៅពេលក្រោយ
- បើអវត្តមាន ១ដង ឬ ២ដង ត្រូវជូនដំណឹងពីមូលហេតុច្បាស់លាស់ជាក់លាក់ ជូនប្រធានក្រុមប្រឹក្សាយោបល់
- ក្រុមនីមួយៗ ត្រូវលើកផែនការក្នុងការប្រឹក្សាយោបល់ជាមួយក្រុមរបស់ខ្លួន ដើម្បីដាក់ជូនលេខាធិការដ្ឋានវេដ+កម្ពុជា និងការផ្តល់ព័ត៌មានពីការប្រជុំត្រូវផ្តល់ឲ្យបានមុន ២សប្តាហ៍
- ការប្រជុំត្រូវកំណត់កន្លែងឲ្យបានសមល្មម
- ធ្វើបែបណាក្នុងការផ្តល់យោបល់ដល់កិច្ចប្រជុំក្រុមការងារវេដ+កម្ពុជា នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣
- តើមានរបៀបវារៈក្នុងកិច្ចប្រជុំក្រុមការងារវេដ+អ្វី ដើម្បីភ្ជាប់ការផ្តល់យោបល់ រវាងក្រុមប្រឹក្សាយោបល់ទៅក្រុមការងារវេដ+
- Celina ផ្តល់យោបល់ថា ក្រុមប្រឹក្សាយោបល់ គួរធ្វើសំណើចូលរួមក្នុងកិច្ចប្រជុំក្រុមការងារវេដ+ ដើម្បីផ្តល់មតិយោបល់ដោយផ្ទាល់
- ក្រុមប្រឹក្សាយោបល់ ថាគួរមានតំណាងចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាយោបល់
- លេខាធិការដ្ឋាន នឹងស្នើយោបល់ថាតើតំណាងក្រុមប្រឹក្សាយោបល់អាចចូលរួមក្នុងកិច្ចប្រជុំក្រុមការងារវេដ+ បានដែរឬទេ
- លេខាធិការដ្ឋានជួយបង្ហាញពីរចនាសម្ព័ន្ធរបស់វេដ+កម្ពុជាក្នុងកិច្ចប្រជុំលើកក្រោយ
- RECOFTC នឹងការផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាយោបល់ (នៅខែតុលា RECOFTC នឹងអញ្ជើញក្រុមប្រឹក្សាយោបល់វេដ+ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវេដ+ ការផ្តល់មតិយោបល់លើវេដ+ និងធ្វើការវាយតម្លៃសម្រាប់វគ្គបណ្តុះបណ្តាល)
- ប្រជុំថ្ងៃលើកក្រោយអាចធ្វើនៅថ្ងៃទី១០ ខែតុលា ឆ្នាំ ២០១៣ នៅខេត្តសៀមរាប
- ក្រុមប្រឹក្សាយោបល់ត្រូវរៀបចំកិច្ចប្រជុំឲ្យបានមុនប្រជុំក្រុមការងារវេដ+
- របៀបវារៈកិច្ចប្រជុំលើកក្រោយរួមមាន៖
    - ការបង្កើតលក្ខន្តិក: បទបញ្ជាផ្ទៃក្នុង តួនាទីភារកិច្ច
    - ការបោះឆ្នោតជ្រើសរើសប្រធាន
    - ស្នើឲ្យតំណាងចូលរួមផ្តល់យោបល់ដល់ក្រុមការងារវេដ+

- ○ សំណើទៅទស្សនកិច្ចសិក្សានៅទីតាំង FFI
- ស្នើសុំលេខាធិការដ្ឋានវេជ+កម្ពុជា ធ្វើការសម្រេចលើការគាំទ្រថវិកាលើការប្រជុំ
- ស្នើឲ្យមានការគាំទ្រមធ្យោបាយទំនាក់ទំនងដល់សហគមន៍ដើម្បីភ្ជាប់បណ្តាញព័ត៌មាន
- សូមឲ្យមានការលើកទឹកចិត្តគាំទ្រដូចគ្នា ដល់សមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់គ្នា
- ប្រធានកិច្ចប្រជុំបន្ទាប់ លោក ឈិត សំអាត ប្រធានអង្គការ NGO Forum។

**សន្និដ្ឋានពីអង្គប្រជុំ**

ក្រោយពីបានពិភាក្សាគ្នាយ៉ាងផុសផុលរួចមក កិច្ចប្រជុំដំបូងក្រុមប្រឹក្សាយោបល់សម្រាប់ការងារវេជ+ សម្រេចបានលទ្ធផលដូចខាងក្រោម៖

១. ការប្រជុំក្រុមប្រឹក្សាយោបល់ធ្វើឡើង២ខែម្តង ក្នុងករណីចាំបាច់ត្រូវធ្វើការប្រជុំវិសាមញ្ញ

២. ក្រុមប្រឹក្សាយោបល់ត្រូវមាន៖ ប្រធាន១រូប អនុប្រធាន១រូប លេខាធិការ១រូប និងសមាជិក

៣. ប្រធានអង្គប្រជុំត្រូវរៀបចំរបៀបវារៈនៃកិច្ចប្រជុំនីមួយៗ ដោយមានជំនួយពីលេខាធិការដ្ឋាន និង មានការឯកភាពពីប្រធានក្រុមប្រឹក្សាយោបល់

៤. ក្រុមការងារនីមួយៗត្រូវរៀបចំស្នើគម្រោងអនុវត្តនានា ជូនលេខាធិការដ្ឋានវេជ+កម្ពុជា

៥. ស្នើលេខាធិការដ្ឋានវេជ+កម្ពុជា ដាក់របៀបវារៈមួយក្នុងអង្គប្រជុំក្រុមការងារវេជ+កម្ពុជា ដើម្បីអនុញ្ញាឲ្យក្រុមប្រឹក្សាយោបល់បានបញ្ចេញទស្សនៈ និងយោបល់

៦. កិច្ចប្រជុំបន្ទាប់នៃក្រុមប្រឹក្សាយោបល់ ក្រុមប្រឹក្សាយោបល់ស្នើសុំរៀបចំឡើងនៅថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ នៅខេត្តសៀមរាប។ ចំពោះសំណើនេះក្រុមការងារលេខាធិការដ្ឋាននឹងជូនដំណឹងនៅពេលក្រោយ។ របៀបវារៈកិច្ចប្រជុំរួមមាន៖ ការបោះឆ្នោតជ្រើសរើសប្រធាន១រូប អនុប្រធាន១រូប លេខាធិការ១រូប ការរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង តួនាទីនិងភារកិច្ច។

៧. ស្នើដល់លេខាធិការដ្ឋានវេជ+កម្ពុជា សម្របសម្រួលរៀបចំសម្ភារៈ និងឯកសារនានា ជូនក្រុមប្រឹក្សាយោបល់

៨. ស្នើឲ្យមានការចូលរួមពីក្រុមប្រឹក្សាយោបល់នៅក្នុងកិច្ចប្រជុំក្រុមការងារវេជ+កម្ពុជា។

កិច្ចប្រជុំត្រូវបានបញ្ចប់នៅម៉ោងប្រាំនិងដប់ប្រាំនាទីនាថ្ងៃខែឆ្នាំដដែលដោយស្មារតីទទួលខុសត្រូវ។

**ប្រធានអង្គប្រជុំ**